**សុន្ទរកថាបិទអង្គសិក្ខាសាលា**

ឯកឧត្តម **គឹម ឆៃហៀង** អភិបាលរងខេត្តសៀមរាប

ក្នុងអង្គសិក្ខាសាលាស្តីពី

**"ការធ្វើសមាហរណកម្មគោលនយោបាយសង្គម និងការ**

**ផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាន"**

ខេត្តសៀមរាបថ្ងៃទី២៩-៣១ ខែឧសភា ឆ្នាំ២០១៣

**ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន**

ក្នុងនាមឯកឧត្តមអភិបាលខេត្តសៀមរាប និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ ដោយបានចូលរួមក្នុងកម្មវិធីបិទអង្គសិក្ខាសាលាស្តីពី "ការធ្វើ សមាហរណកម្មគោលនយោបាយសង្គម និងការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាន" ដែលរៀបចំដោយ អង្គការអន្តរជាតិខាងការងារ សហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។ យើងខ្ញុំពិតជាមានមោទនភាព ដែលខេត្តសៀមរាបត្រូវបានជ្រើសរើសជាទីតាំងសំរាប់អង្គសិក្ខាសាលានេះ ដើម្បីអោយភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ មានឳកាសទស្សនា និងស្វែងយល់ពីប្រវត្តិសាស្ត្រដ៏អស្ចារ្យរបស់ប្រទេសកម្ពុជា ដែលបង្ហាញឱ្យឃើញពីសម្បត្តិវប្បធម៌ដ៏សម្បើមរបស់កម្ពុជាដែលជា **ព្រះរាជាណាចក្រ អច្ឆរិយៈ** ។

ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន

ឆ្លងកាត់ការផ្លាស់ប្តូរបទពិសោធន៍ យោបល់ និងការពិភាក្សាយ៉ាងស្វាហាប់អស់រយៈពេលពីរថ្ងៃកន្លះនេះ សិក្ខាកាមទាំងអស់ ពិតជាទទួលបាននូវបទពិសោធន៍និងចំណេះដឹងល្អៗជាច្រើន ហើយខ្ញុំសង្ឃឹមថា **ឯកឧត្តម លោក លោកស្រី** នឹងយកទៅកែច្នៃ និងអនុវត្ត ដោយផ្អែកទៅតាមបរិបទនៃប្រទេសរៀងៗខ្លួន។ ជាពិសេស តាមរយៈបទបង្ហាញដ៏ក្បោះក្បាយរបស់ឯកឧត្តម **ហេង សួរ** បានបញ្ជាក់យ៉ាងច្បាស់ថា សិក្ខាកាមកម្ពុជា ទទួលបានចំណេះដឹងយ៉ាងច្បាស់អំពីវិធីសាស្ត្រល្អៗ ជាច្រើនក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមតាមរយៈការសម្របសម្រួលផ្សេងៗ និងលោកស្រី **មេហ្គា អ៊ីរ៉េណា** (Ms. Mega Irena) ដែលបានបញ្ជាក់ពីទិសដៅអនុវត្តនាពេលអនាគតរបស់អាស៊ាន លើការយកចិត្តទុកលើកិច្ចគាំពារសង្គមក្នុងក្របខ័ណ្ឌអាស៊ានក្នុងការកាត់បន្ថយភាពក្រីក្រនិងភាពងាយរងគ្រោះ ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។

ដូចដែលយើងបានជ្រាបក្នុងឱកាសបើកអង្គសិក្ខាសាលានេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានមានប្រសាសន៍ដ៏ខ្លង់ខ្លស់ថា ការសម្របសម្រួល គឺជាសសរស្តម្ភយ៉ាងសំខាន់នៃការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម ដូចដែលមានចែងក្នុងយុទ្ធសាស្ត្រនេះថា "ប្រការសំខាន់នៃការសម្របសម្រួល គឺការបង្កើតរចនាសម្ព័ន្ធ និងយន្តការសមស្របមួយដើម្បីសម្របសម្រួលដល់ការបង្កើត និងការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គម ដែលធានាឱ្យមានការត្រួតពិនិត្យគោលនយោបាយ ការពិនិត្យតាមដាននិងវាយតម្លៃ ការគ្រប់គ្រងចំណេះដឹង ពត៌មាន និងការកសាងសមត្ថភាព"។

សិក្ខាសាលានេះក៏បានរកឃើញថា យន្តការការសម្របសម្រួល ពិតជាមានសារៈសំខាន់ណាស់នៅថ្នាក់គោលនយោបាយ ហើយជាបញ្ហាចាំបាច់មួយ គឺថា កម្ពុជាគួរតែពង្រឹងក្រុមការងារអន្តរក្រសួងដែលមានស្រាប់ រួមមានក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងអប់រំ ក្រសួងសង្គមកិច្ច ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួង ស្ថាប័ន ពាក់ព័ន្ធដទៃផ្សេងៗទៀត។ ជាងនេះទៀត ការសម្របសម្រួល ក៏ជាកត្តាមួយដ៏ចំបងក្នុងការផ្តល់សេវាសង្គម ហើយយើងខ្ញុំរីករាយ និងសូមស្វាគមន៍ ចំពោះការរៀបចំបង្កើតយន្តការផ្តល់សេវាគាំពារសង្គម (Social Service Delivery Mechanism-SSDM) ដូចដែលឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** បានមានប្រសាសន៍។ យន្តការនេះ ជាកន្លែងចំណតតែមួយនៅថ្នាក់ស្រុក និងថ្នាក់ឃុំ និងជាការិយាល័យមួយដែលមានគោលបំណងសម្របសម្រួល ការប្រើប្រាស់ទាំងសេវាគាំពារសង្គម និងសេវាការងារ។ សេវានេះ ត្រូវស្ថិតនៅក្នុងស្ថាប័នរដ្ឋាភិបាល និងត្រូវប្រតិបត្តិដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដូចនេះ វាមិនត្រឹមតែជាយន្តការមួយ ដែលជួយអោយមានស្ថេរភាពក្នុងការអនុវត្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយពង្រឹងប្រតិភូកម្មអំណាច និងផ្តល់សិទ្ធិដល់រដ្ឋបាលថ្នាក់ក្រោមជាតិអោយកាន់តែមានប្រសិទ្ធិភាពខ្ពស់ថែមទៀត។

យើងខ្ញុំ សូមស្វាគមន៍និងមានសេចក្តីសោមនស្សរីករាយចំពោះការជ្រើសរើសជាខេត្ត សាកល្បងទី១ ក្នុងការអនុវត្តយន្តការផ្តល់សេវាគាំពារសង្គមនៅក្នុងទឹកដីខេត្តសៀមរាប។ យើងខ្ញុំបានត្រៀមខ្លួនរួចជាស្រេច ក្នុងការសម្របសម្រួលការអនុវត្តការងារយន្តការនេះ និងត្រៀមបញ្ជូនមន្ត្រី ពាក់ព័ន្ធទាំងឡាយ ដើម្បីចូលរួមសហការណ៍អនុវត្តគំរោងយន្តការផ្តល់សេវាគាំពារសង្គមនេះនៅក្នុងស្រុកអង្គរជុំ និងស្រុកស្រីស្នំ។ ជាមួយគ្នានេះដែរ ខេត្តនឹងពង្រឹងថែមទៀតនូវសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិដើម្បីធានាដល់ការអនុវត្តយន្តការផ្តល់សេវាគាំពារសង្គមនេះ និងផែនការអនុវត្ត៣ឆ្នាំរំកិល(IP3)

អោយកាន់តែល្អប្រសើរ និងត្រៀមអនុវត្តការពង្រីកវិសាលភាពយន្តការនេះជាបន្តទៀត នៅទូទាំងខេត្តសៀមរាប ដើម្បីជាគំរូសំរាប់យកទៅអនុវត្តក្នុងខេតដ៏ទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមឆ្លៀតឱកាសនេះ សូមសម្តែងនូវសេចក្តីថ្លែងអំណរគុណជាថ្មីម្តងទៀត ចំពោះក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងអង្គការអន្តរជាតិខាងការងារ ដែលផ្តល់កិត្តិយសដល់ខ្ញុំ ក្នុងការចូលរួមបិទអង្គសិក្ខាសាលានេះ ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោក លោកស្រី ភ្ញៀវជាតិនិងអន្តរជាតិទាំងអស់ ដែលបានអញ្ជើញមកពីប្រទេសជាច្រើនដូចជា អាហ្សង់ទីន ប្រេស៊ីល ប្រ៊ុយណេ ឈិលី កូឡុំប៊ី បារាំង ឥណ្ឌា ឥណ្ឌូនេស៊ី ជប៉ុន សាធារណៈរដ្ឋកូរ៉េ ឡាវ ម៉ាឡេស៊ី ម៉ុងហ្គោលី ភូមា ណាមីប៊ី ប៉ាគីស្ថាន ហ្វីលីពីន សូឡូម៉ុន អាហ្វ្រិកខាងត្បូង ថៃ វៀតណាម វ៉ានូទូ ហ្សមប៊ី និងមកពីស្ថាប័នសំខាន់ៗទៀតក្នុងការចូលរួមចែករំលែកគំនិត បទពិសោធន៍ និងចំណេះដឹងល្អៗសំរាប់ជាទុនក្នុងការអនុវត្តយុទ្ធសាស្រ្តជាតិគាំពារសង្គមនៅកម្ពុជា និងអាស៊ានក្នុងទិសដៅសម្រេចឱ្យបាននូវកិច្ចគាំពារសង្គមជាមូលដ្ឋានដល់ប្រជាជនគ្រប់ៗរូបជាពិសេសជនក្រីក្រ និងជនងាយរងគ្រោះ។

ជាចុងបញ្ចាប់ សូមឱ្យដំណើរស្នាក់នៅបន្ត និងដំណើរត្រលប់ទៅវិញរបស់ឯកឧត្តម លោក លោកស្រី ភ្ញៀវអន្តរជាតិ និងជាតិទាំងអស់ ប្រកបដោយភាពរីករាយ និងសូមប្រកាស**បិទ**អង្គសិក្ខាសាលាស្តីពី "ការធ្វើសមាហរណកម្ម គោលនយោបាយសង្គម និងការផ្តល់សេវាគាំពារសង្គមជាមូលដ្ឋាន" ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**